# មេរៀនទី ៨៧៖ សត្វលារបស់បាឡាមចេះនិយាយ

## ជនគណនា ២២៖១-៣៨

**មេរៀន** ( *យូធូបលីង* )៖ https://youtu.be/rBWjUkR7q08

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/UNTASaSDXKo

**គោលបំណង៖** ព្រះជួយយើងឲ្យស្តាប់បង្គាប់ទ្រង់។

**ខគម្ពីរចងចាំ៖** ទំនុកដំកើង១២១៖២ *"សេចក្តីជំនួយរបស់ខ្ញុំមកតែពីព្រះយេហូវ៉ាទេ គឺជាព្រះដែល បង្កើតផ្ទៃមេឃ និងផែនដី។"*

**ចំរៀង** ( *យូធូបលីង* )៖
១. ក្នុងព្រះនាមព្រះយេស៊ូវ https://youtu.be/0b41QksexPE
២. ខ្ញុំថ្វាយបង្គំដ្បិតទ្រង់ជាព្រះ https://youtu.be/1C4guXZFdAw
៣. បាបខ្ញុំរួចអស់ហើយ https://youtu.be/zosjd2E8cmE

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត "ធ្វើសម្លេងឆ្មា និងឆ្កែ"




១.សូមឲ្យកុមារអង្គុយឬក៏ឈរជារង្វង់។
២.អ្នកចាំទីម្នាក់ផ្តើមលេងមុនគេដោយគាត់ងាកទៅខាងស្តាំស្រែកធ្វើជាលំលេង សត្វឆ្មា(ម៉េវៗ)។
៣.បន្ទាប់មកអ្នកនៅខាងស្តាំដែលនៅបន្ទាប់ពីអ្នកចាំទីនោះត្រូវធ្វើសំលេងដូចគ្នា(ម៉េវៗ)។
៤.បើអ្នកចាំទីនោះងាកមកឆ្វេងវិញត្រូវធ្វើជាសំលេងសត្វឆ្កែ(វ៉ូសៗ) ដោយអ្នកនៅខាងឆ្វេង បន្ទាប់ពីគាត់ ត្រូវធ្វើសំលេងដូចគ្នា (វ៉ូសៗ)។
៥. អ្នកដែលធ្វើខុសគឺជាអ្នកដែលចាញ់ល្បែងនេះ។




### ៤. ការណែនាំមេរៀន

រាស្ត្ររបស់ព្រះដែលជាជនជាតិអ៊ីស្រាអែលបានរត់ចេញពីអេហ្ស៊ីប ជាកន្លែងដែលពួកគេធ្លាប់ធ្វើជាទាសករនៅទីនោះ។ ដោយសារជនជាតិអ៊ីស្រាអែលមិនបានទុកចិត្តព្រះ ពួកគេត្រូវវង្វេងនៅក្នុងទីរហោស្ថានអស់រយៈពេល ៤០ឆ្នាំ។ នៅពេលពួកគេកំពុងធ្វើដំណើរទៅទឹកដីសន្យា ពួកគេបានបោះជំរំនៅក្បែរទន្លេ- យ័រដាន់។ ព្រះតែងតែចង់ឱ្យពួកយើងស្តាប់បង្គាប់ទ្រង់។ នៅពេលដែលយើងមានការលំបាកក្នុងការស្តាប់បង្គាប់ព្រះនោះទ្រង់សន្យាថា នឹងជួយដល់យើង។ ថ្ងៃនេះយើងនឹងរៀនអំពីបុរសម្នាក់ឈ្មោះបាឡាមដែលត្រូវការជំនួយពីព្រះដើម្បីឲ្យគាត់ស្តាប់បង្គាប់ទ្រង់។

### ៥. រឿងនៅក្នុងព្រះគម្ពីរ

បាឡាមជាបុរសម្នាក់ដែលតែងតែព្យាយាមប្រាប់ពីរឿងរ៉ាវនាពេលអនាគត(ហោរា)។ បាឡាកដែលជាស្តេចស្រុក ម៉ូអាប់ ខ្លាចជនជាតិអ៊ីស្រាអែល ព្រោះគាត់គិតថាពួកគេនឹងមកឈ្លានពានទឹកដីរបស់គាត់

ហើយលួចយក ប្រទេសរបស់គាត់ទៅ។ គាត់បានសុំបាឡាមឲ្យដាក់បណ្តាសាលើជនជាតិអ៊ីស្រាអែល ដើម្បីបំភ័យពួកគេឲ្យចេញទៅ ប៉ុន្តែបាឡាមមិនធ្វើទេ។ គាត់មិនអាចដាក់បណ្តាសាជនជាតិ អ៊ីស្រាអែលទេ។ ដោយព្រោះព្រះបានប្រាប់គាត់ថា ជនជាតិអ៊ីស្រាអែលគឺជាមនុស្សដែលមានពរ។ ស្តេចចង់ផ្លាស់ប្តូរគំនិតរបស់បាឡាម ដូច្នេះគាត់បានអញ្ជើញបាឡាមទៅរាជវាំង។ គាត់មានគម្រោងផ្តល់រង្វាន់យ៉ាងធំដល់បាឡាមដើម្បីឲ្យគាត់ដាក់បណ្តាសាលើជនជាតិអ៊ីស្រាអែល។ ព្រះបានប្រាប់បាឡាមថាគាត់អាចទៅជួបស្តេចបាន ប៉ុន្តែទ្រង់បានព្រមាន បាឡាមឱ្យនិយាយតែអ្វីដែលព្រះមានបន្ទូលឲ្យគាត់និយាយតែប៉ុណ្ណោះ។

នៅថ្ងៃបន្ទាប់បាឡាមបានជិះសត្វលា ដើម្បីទៅជួបស្តេច ប៉ុន្តែព្រះបានខឹងនឹងបាឡាម។ ព្រះអង្គដឹងថាក្នុងចិត្តរបស់បាឡាមគឺមិនស្មោះត្រង់នោះទេ ។ ចំពោះព្រះ ការស្តាប់បង្គាប់ឲ្យអស់ពីចិត្តរបស់បាឡាមចំពោះទ្រង់គឺសំខាន់ណាស់ ដូច្នេះព្រះអង្គបានចាត់ ទេវតាដើម្បីទៅរាំងផ្លូវសត្វលារបស់បាឡាមចំនួន ៣ ដង ប៉ុន្តែបាឡាមនៅតែរឹងចចេសបន្តដំណើរទៅមុខទៀត។ ដោយសារគាត់មើលមិនឃើញទេវតា ដូច្នេះហើយទើបបាឡាមចេះតែឆ្ងល់ថាហេតុអ្វីបានជាសត្វលារបស់គាត់ចេះតែឈប់ដើរ។ គាត់បានវាយសត្វលាញីរបស់គាត់ឲ្យដើរ។ នៅទីបំផុតព្រះបានធ្វើឲ្យសត្វលានោះនិយាយជាមួយបាឡាម។ ហើយវាពិតជាអស្ចារ្យណាស់ដែលសត្វចេះនិយាយ! តែវាជាការពិតដែលព្រះបានធ្វើឱ្យសត្វលាអាចនិយាយជាមួយបាឡាមបាន!

រំពេចនោះបាឡាមក៏អាចមើលឃើញទេវតា។ ហើយគាត់បានដឹងច្បាស់ថាតើព្រះចង់បានអ្វី គាត់បានត្រៀមខ្លួនជាស្រេចដើម្បីស្តាប់បង្គាប់ទ្រង់ដោយអស់ពីចិត្ត ។ ព្រះបានព្យាយាមធ្វើយ៉ាងណា ដើម្បីឲ្យបាឡាមស្តាប់បង្គាប់ទ្រង់! ព្រះបានបញ្ជូនទេវតាមួយអង្គដើម្បីមកបញ្ឈប់ការធ្វើដំណើររបស់គាត់ ហើយដើម្បីជាការទាក់ទាញចំណាប់អារម្មណ៍របស់បាឡាមទ្រង់បាន ធ្វើឱ្យសត្វលាដែលគាត់ជិះចេះនិយាយ! ព្រះអង្គយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការស្តាប់បង្គាប់ ហើយទ្រង់នឹងសព្វព្រះហឫទ័យធ្វើអ្វីៗដើម្បីជួយយើង។ នៅក្នុងចំណោមរបស់ជាច្រើន ទ្រង់បានផ្តល់ឲ្យយើងនូវ ព្រះគម្ពីរ ឪពុកម្តាយ គ្រូបង្រៀន និងព្រះវិញ្ញាណបរិសុទ្ធ។ ព្រះជួយយើងអោយស្តាប់បង្គាប់ទ្រង់។

## ៦. សំនួរពិភាក្សា

១.ហេតុអ្វីបានជាស្តេចបាឡាកមានអារម្មណ៍ភ័យខ្លាច?(*គាត់ខ្លាចជនជាតិអ៊ីស្រាអែលនឹងមកកាន់កាប់ប្រទេសរបស់គាត់*)

២. តើស្តេចបាឡាកចង់ឲ្យបាឡាមធ្វើអ្វី?(*ដាក់បណ្តាសាអ៊ីស្រាអែល ដើម្បីឱ្យរឿងអាក្រក់កើតឡើងលើជនជាតិអ៊ីស្រាអែល*)

៣. ហេតុអ្វីបានជាព្រះខឹងនឹងបាឡាម? (*ដោយសារតែចិត្តរបស់គាត់រឹងរូសមិនទាន់ត្រៀមខ្លួនដើម្បីស្តាប់បង្គាប់ព្រះទេ គាត់ចង់ទទួលបានរង្វាន់ច្រើនជាងគោរពតាមព្រះ*)

៤. ហេតុអ្វីបានជាព្រះធ្វើឱ្យសត្វលានិយាយជាមួយបាឡាម? (*ដើម្បីឱ្យបាឡាមចាប់អារម្មណ៍ព្រោះបាឡាមមិនបានធ្វើតាមអ្វីដែលព្រះចង់ឱ្យគាត់ធ្វើ*)

៥. តើអ្នកគួរធ្វើអ្វីនៅពេលអ្នកត្រូវការជំនួយដើម្បីស្តាប់បង្គាប់ព្រះ? (*សុំឱ្យព្រះជួយអ្នកព្រោះព្រះតែងតែជួយយើងឲ្យស្តាប់បង្គាប់ព្រះអង្គ!*)

៦. តើប្អូនៗអាចធ្វើអ្វីខ្លះដើម្បីបង្ហាញថាប្អូនស្តាប់បង្គាប់ព្រះ?

## ៧. ល្បែងកំសាន្ត « ចំណងមនុស្ស »



១.កុមារមិនអាចនិយាយបានទេនៅពេលប្រកួត។

ជ្រើសរើសសិស្សម្នាក់ឱ្យធ្វើជាមេក្រុម។

២.ឱ្យកុមារទាំងអស់(លើកលែងតែមេក្រុម) ឈរជារង្វង់មួយ ដោយដាក់

ដៃទាំងពីររបស់ពួកគេចេញ ទៅមុខ ហើយចាប់ដៃសិស្ស២នាក់ផ្សេងទៀត ឥឡូវនេះពួកគេមើលទៅដូចជាកំពុងចងជាប់គ្នាអញ្ចឹង។(គ្រូមានសិទ្ធិក្នុងការជ្រើសរើសថាតើមួយក្រុមមានកុមារប៉ុន្មាននាក់)

៣. ពួកគេត្រូវព្យាយាមដោះខ្លួនពីចំណង ប៉ុន្តែមិនអាចនិយាយគ្នា ឬ លែងដៃពីគ្នាបានទេ។

៤.មានតែមេក្រុមម្នាក់ទេដែលអាចនិយាយនិងផ្តល់ការណែនាំដល់កុមារផ្សេងទៀត ដើម្បីជួយពួកគេដោះខ្លួនឲ្យរួច។ ពួកគេត្រូវស្តាប់តាមមេក្រុម។

បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថាពេលខ្លះ ជីវិតយើងគឺបែបនេះ។ យើងត្រូវរង់ចាំព្រះដើម្បីជួយដោះយើងចេញពីបញ្ហា។ ដូចជាមេក្រុមបានជួយប្អូនឱ្យរួចផុតពីចំណងអញ្ចឹងដែរ ព្រះសន្យាថានឹង ជួយយើងស្តាប់ឲ្យតាមបង្គាប់ទ្រង់។ ហើយនៅចុងបញ្ចប់ព្រះជាម្ចាស់នឹងធ្វើឱ្យអ្វីៗប្រែជាអស្ចារ្យ។ ការងារ របស់យើង គឺទុកចិត្ត និងធ្វើតាមអ្វីដែលទ្រង់បង្គាប់ ហើយទ្រង់នឹងជួយយើងឲ្យធ្វើការនោះបាន។

## ៨. ខគម្ពីរចងចាំ

**ទំនុកដំកើង១២១:២** "សេចក្តីជំនួយរបស់ខ្ញុំមកតែពីព្រះយេហូវ៉ាទេគឺជាព្រះដែលបង្កើតផ្ទៃមេឃ និងផែនដី។"

## ៩. ហាត្ថកម្ម «តោះនាំគ្នាធ្វើទេវតា»



១. ចែកចានក្រដាសឲ្យសិស្ស (បើមិនអាចរកចានក្រដាសបានសូមកាត់ក្រដាសជារាងរង្វង់មូលក៏បាន) ម្នាក់មួយ។

២. កាត់ចានក្រដាសនោះ មួយជ្រុងល្មម (ប្រហែលជា ១ភាគ៦នៃចាន) ហើយយកវាទៅបិទនៅផ្នែក កណ្តាលនៃចានក្រដាសនោះ (ទល់គ្នាជាមួយនឹងជ្រុងទទេរដែលកាត់ចេញ)។

៣. កាត់រង្វង់មូលមួយពីក្រដាសផ្សេងទៀតដើម្បីធ្វើជាមុខទេវតា។

៤. តុបតែងវាដោយប្រើប៊ិចផ្លេកៗឬប៊ិចពណ៌ហើយសរសេរពាក្យថា "ស្តាប់បង្គាប់ព្រះ" នៅលើរូបទេវតានោះ។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ: (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយអ្នកណាដែលមានទំនាក់ទំនងជាមួយព្រះយេស៊ូវ។ ព្រះបានប្រើយើងរាល់ថ្ងៃដើម្បីធ្វើការអស្ចារ្យ និងបង្ហាញអំណាចរបស់ព្រះអង្គនៅក្នុងជីវិតរបស់យើង ហើយនៅក្នុងជីវិតអ្នកដទៃផ្សេងទៀត។ សូមក្រឡេកមើលពីបទពិសោធន៍មួយចំនួនកន្លងមក ដែលអ្នកបានឃើញព្រះហស្ត របស់ព្រះអង្គបានធ្វើការផ្ទាល់។ សូមសញ្ជឹងគិត២ទៅ៣នាទី ដើម្បីអរព្រះគុណព្រះចំពោះរឿងរ៉ាវទាំងអស់នោះ ហើយចាប់ផ្តើមអធិស្ឋានសុំឱ្យអ្នកមានឱកាសបានចែកចាយពីបទពិសោធន៍ទាំងអស់នោះជាមួយមនុស្ស ដែលត្រូវការស្តាប់ពីបទពិសោធន៍ទាំងអស់នោះ។ អ្នកនឹងមានការភ្ញាក់ផ្អើលពេលដែលឃើញផលផ្លែនៃការអធិស្ឋាននេះ។